# គម្រោងអាជីវកម្មដាំណាំម្ទេសហាវៃ ក្នុងផ្ទះសំណាញ់



រៀបចំដោយ
គណៈកម្មការគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាលនៃ
ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (អេ.អ.ឌី.ប៊ី)

ខែមីនា ឆ្នាំ២០២៤

# មាតិកា


១- សេចក្ដីផ្ដើម ១

២- ការអនុវត្តការដាំដុះ ១

ក- ការរៀបចំដី ១

ខ- ល្បាយដីបណ្ដុះកូន ១

គ- ការរៀបចំប្រព័ន្ធទឹក ១

ឃ- ការជ្រើសរើសពូជ ១

ង- លក្ខខណ្ឌអាកាសធាតុ និងពន្លឺ ២

ច- វិធីដាំដុះ ២

ឆ- ការថែទាំ ២

ជ- ការដាក់ជី ២

ឈ- កត្តាចង្រៃ ៣

ញ- អាយុកាលដាំដុះ និងប្រមូលផល ៣

៣- តម្រូវការទុនដំបូងក្នុងការដាំដុះម្ទេសហាវៃ សម្រាប់ផ្ទៃដីទំហំ ១០ អា ៤

៤- ការវិភាគសេដ្ឋកិច្ចលើការដាំដុះម្ទេសហាវៃ សម្រាប់ផ្ទៃដីទំហំ ១០ អា ៤

៥- លទ្ធភាពចំណេញផ្អែកលើនិន្នាការតម្លៃ លើផ្ទៃដីទំហំ ១០ អា ៥

៦- ខ្សែច្រវាក់តម្លៃ ៥

៧- ហានិភ័យ ៦

៨- សេចក្ដីសន្និដ្ឋាន ៦

# ដំណាំម្ទេសហាវៃ

## ១-សេចក្តីផ្តើម

ម្ទេសហាវៃមានអត្ថប្រយោជន៍ជាច្រើននៅក្នុងរបបអាហារប្រចាំថ្ងៃដូចជា យកទៅបរិភោគជាបន្លែស្រស់ ចំអិនជាមួយសាច់ ឆា ឬស្ល បានច្រើនមុខ និងអាចកិន ឬកៀបយកទឹកធ្វើជាភេសជ្ជៈផងដែរ។ ម្ទេសហាវៃមានពូជជាច្រើនដូចជាពូជពណ៌លឿង ពណ៌ក្រហម ពណ៌ទឹកក្រូច និងពណ៌ស្វាយជាដើមនៅពេលទុំ។ ជាទូទៅសម្រាប់ទីផ្សារក្នុងស្រុកភាគច្រើនសង្កេតឃើញលក់ម្ទេសហាវៃពណ៌បៃតងជាម្ទេសមិនទាន់ទុំល្អ ដែលជាតម្រូវការរបស់ទីផ្សារក្នុងស្រុក និងការនិយមរបស់អ្នកបរិភោគ។

## ២-ការអនុវត្តការដាំដុះ

**ក. ការរៀបចំដី÷** ភ្ជួរដីឱ្យម៉ដ្ឋល្អពី ២ ទៅ ៣សារ រួចហាលដីទុករយៈពេលពី ១០ ទៅ ១៥ថ្ងៃ។ ឆ្ងួតពូនជារង ដែលមានទទឹងរងខ្ទង់លើ ០.៨ម៉ែត្រ និងបាតរង ១ម៉ែត្រ ដោយទុកចន្លោះពីពាក់កណ្តាលរងមួយទៅពាក់កណ្តាលរងមួយប្រវែង ១.៥ម៉ែត្រ។ ការដាំពីរជួរគួរតែប្រើជាំជាមុំចង្ក្រានដើម្បីងាយគ្រប់គ្រងកត្តាចង្រៃ ងាយគ្រប់គ្រងជីជាតិ និងទទួលពន្លឺបានល្អប្រសើរជាងដាំទន្ទឹមគ្នា។ ប្រើប្រាស់ជីធម្មជាតិទ្រាប់បាតក្នុងបរិមាណ ៥០០ ទៅ ១,៥០០គីឡូក្រាម/១០០០ម៉ែត្រការ៉េ (តាមលទ្ធភាព និងគុណភាពដី)។

**ខ. ល្បាយដីបណ្តុះកូន ÷** ល្បាយដីបណ្តុះកូនម្ទេសរួមមាន ដីដំបូក ឬដីទន្លេ ១ភាគ៣ លាយជាមួយធ្យូងអង្កាម ១ភាគ៣ និងកំប៉ុស្ត ១ភាគ៣ ច្របល់ចូលគ្នា បន្ទាប់មកលីង ឬចំហុយសម្លាប់មេរោគស្មៅចង្រៃ។ ផ្អាប់ទុកដីបណ្តុះកូនជាមួយត្រៃកូឌឺម៉ា (Trichoderma) ១គ.ក សម្រាប់ល្បាយដី ១តោនដើម្បីកម្ចាត់ជំងឺផ្សិតចង្រៃ។

**គ. ការរៀបចំប្រព័ន្ធទឹក÷** ប្រើប្រាស់ប្រព័ន្ធដំណក់ទឹកទ្រប់ គឺសមស្របសម្រាប់ដំណាំម្ទេសហាវៃ។

**ឃ. ការជ្រើសរើសពូជ÷**ពូជម្ទេសហាវៃមួយចំនួនដែលមានវត្តមាននៅកម្ពុជា÷



SWEET PEPER
PSW-2059



SWEEP PEPER
PSW-2128



SWEET PEPER
PSW-2060



SWETT PEPER
PSW-2064



ពូជ មេគង្គ
MEKONG F1

**ង. លក្ខខណ្ឌអាកាសធាតុ និងពន្លឺ÷** ដំណាំម្ទេសហាវៃដាំបានគ្រប់រដូវកាល អាចលូតលាស់បានល្អនៅសីតុណ្ហភាពចន្លោះពី ២០-២៥$^{0}$C ក្នុងអត្រាសំណើមបរិយាកាសមធ្យម ធ្វើឱ្យម្ទេសលូតលាស់បានល្អ និងទទួលទិន្នផលខ្ពស់។

**ច. វិធីដាំដុះ÷** ត្រូវយកកូនម្ទេសដែលបណ្ដុះបានអាយុពី ១៨ ទៅ ២៥ថ្ងៃ ពីថាសបណ្ដុះមកដាំលើរងដែលបានលើករួចរាល់ ដោយដាំក្នុងចន្លោះគុម្ព ៦០ស.ម និងចន្លោះជួរលើរងតែមួយ ៦០ស.ម។




**ឆ. ការថែទាំ÷** ត្រូវស្រោចទឹក២ដងក្នុងមួយថ្ងៃគឺនៅពេលព្រឹកម្តង និងពេលរសៀលម្តង។ បន្ទាប់ពីដាំបានរយៈពេល៧ថ្ងៃឡើងទៅត្រូវមានកាលវិភាគប្រើប្រាស់ថ្នាំជីវសាស្ត្រ និងថ្នាំពុលកសិកម្មបង្ការជំងឺ និងសត្វល្អិតសម្រាប់ការពារកត្តាចង្រៃផ្សេងៗជាមុន។

**ជ. ការដាក់ជី÷** ក្រោយការដាំដុះរួចរាល់ត្រូវមានកម្មវិធីប្រើប្រាស់ជីសម្រាប់ដំណាំម្ទេសហាវៃ កសិករអាចប្រើប្រាស់ប្រភេទជីទឹកនៅដំណាក់កាលលូតលាស់ដោយបញ្ចូលតាមប្រព័ន្ធដំណក់ទឹក និង ការបាញ់បន្ថែមទៅលើស្លឹក។ សារធាតុចម្បងៗបី N P និង K ដែលជាតម្រូវការចាំបាច់សម្រាប់ការដុះលូតលាស់ ភាពធន និងផ្កាផ្លែរបស់ម្ទេស។ ក្រៅពីនេះសារធាតុ Trace Element (TE)ពិតជារួមចំណែកយ៉ាងសំខាន់ដល់គុណភាពផលិតផល ទិន្នផល និងរូបរាងបំពេញតម្រូវការទីផ្សារ។

**ឈ. កត្តាចង្រៃ÷** ជាទូទៅកសិករតែងជួបប្រទះជាញឹកញាប់នូវកត្តាចង្រៃដែលបំផ្លាញដំណាំម្ទេសហាវៃមានដូចជា រុយស ចៃអេហ្វីដ ពីងពាងក្រហម ទ្រីព ដង្កូវ ណេម៉ាតូដ ជំងឺផ្សិត និងវីរុសជាដើម។



**ញ. អាយុកាលដាំដុះ និងប្រមូលផល÷** ជាធម្មតាម្ទេសហាវៃគេបេះយកផ្លែដែលចាស់សមស្រប ទៅនឹងទីផ្សារ ព្រោះម្ទេសប្រភេទនេះភាគច្រើនប្រើប្រាស់ជាបន្លែ។ លក្ខណៈផ្លែដែលអាចបេះបានគឺពណ៌បៃតងក្រម៉ៅ រលោង រឹង (សម្រាប់ទីផ្សារម្ទេសពណ៌បៃតង)។ វិធីសាស្រ្តប្រមូលផល គេប្រើកន្រ្តៃ ឬ កាំបិតមុតកាត់ផ្តាច់ទង ហើយយកផ្លែទៅរក្សាទុកក្រោមម្លប់ដើម្បីរក្សាពណ៌សម្បកនៃផ្លែ បន្ទាប់មកដាក់បញ្ចូលទៅក្នុងឡាំង ឬកេសដែលធ្វើពីជ័រ ឬក្រដាសស្ដួត (បញ្ជូនទៅរក្សាទុកនៅឃ្លាំងត្រជាក់ ដើម្បីរក្សាគុណភាព និងពន្យាភាពទុំរបស់ផ្លែម្ទេសហាវៃ)។ អាយុកាល និងទិន្នផល គឺអាស្រ័យទៅលើប្រភេទពូជ និងលក្ខខណ្ឌដាំដុះ ថែទាំ។ ម្ទេសហាវៃអាចប្រមូលផលនៅអាយុពី ៦៥ ទៅ ៧០ ថ្ងៃក្រោយពេលដាំកូនម្ទេស និងអាចប្រមូលផលបានពី ៤៥-៦០ ថ្ងៃ។

## ៣-តម្រូវការទុនដំបូងក្នុងការដាំដុះម្ទេសហាវៃ សម្រាប់ផ្ទៃដីទំហំ ១០ អា

| បរិយាយ | ចំនួនទឹកប្រាក់ (រៀល) |
|---|---|
| ចំណាយលើការដាំដុះ | 1,640,000 |
| ចំណាយលើប្រព័ន្ធស្រោចស្រព | 2,740,000 |
| ផ្ទះសំណាញ់ និងសម្ភារៈផ្សេងៗ | 62,520,000 |
| **សរុប** | 66,900,000 |

## ៤-ការវិភាគសេដ្ឋកិច្ចលើការដាំដុះម្ទេសហាវៃ សម្រាប់ផ្ទៃដីទំហំ ១០ អា

-បទពិសោធន៍÷ ការដាំដុះរបស់កសិករនៅសង្កាត់រលាប ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់

-ទិន្នផល÷ ២,៣០០ គ.ក

-តម្លៃជាមធ្យម÷ ៧,០០០រៀល/គ.ក

| បរិយាយ | ឯកត្តា | ចំនួនឯកត្តា | តម្លៃ/ឯកត្តា (រៀល) | ទឹកប្រាក់ (រៀល) | ចំនួនសាររំលស់ | ទឹកប្រាក់សរុប (រៀល) |
|---|---|---|---|---|---|---|
| **១-ចំណូលពីការលក់** | គ.ក | 2,300 | 7,000 | 16,100,000 | | 16,100,000 |
| **២-ចំណាយសរុប = ចំណាយប្រែប្រួល + ចំណាយមិនប្រែប្រួល** | | | | | | 5,990,000 |
| **២.ក-ចំណាយប្រែប្រួលសរុប** | | | | | | 1,640,000 |
| ពូជ | កញ្ចប់ | 3 | 40,000 | 120,000 | | 120,000 |
| ជីកំប៉ុស (លាមកគោ) | តោន | 1 | 500,000 | 500,000 | | 500,000 |
| ជីលាមកសត្វ (មាន់) | ការ៉ុង | 70 | 3,000 | 210,000 | | 210,000 |
| ជីដេអាប៉េ (18-46-00) | ការ៉ុង | 1 | 175,000 | 175,000 | | 175,000 |
| ជីកាលី (00-00-60) | ការ៉ុង | 1 | 85,000 | 85,000 | | 85,000 |
| ថ្នាំសម្លាប់សត្វល្អិត + ជំងឺ | ឈុត | 1 | 130,000 | 130,000 | | 130,000 |
| ថ្លៃកម្មករដាំ និងថែទាំ | នាក់/ថ្ងៃ | 10 | 30,000 | 300,000 | | 300,000 |
| ថ្លៃអគ្គិសនី | វគ្គ | 1 | 120,000 | 120,000 | | 120,000 |
| **២.ខ-ចំណាយមិនប្រែប្រួលសរុប** | | | | | | 4,350,000 |
| ផ្ទះសំណាញ់ 20m x50m (ប្រើ៥ឆ្នាំ) | ផ្ទះ | 1 | 60,000,000 | 60,000,000 | 15 | 4,000,000 |

| | | | | | | |
|---|---|---|---|---|---|---|
| ម៉ាស៊ីនវាយដី(ប្រើ៥ឆ្នាំ) | គ្រឿង | 1 | 2,400,000 | 2,400,000 | 15 | 160,000 |
| ប្រព័ន្ធទឹក (ប្រើ២ឆ្នាំ) | ឈុត | 1 | 500,000 | 500,000 | 6 | 83,333 |
| ម៉ូទ័របូមទឹក(ប្រើ៣ឆ្នាំ) | គ្រឿង | 1 | 240,000 | 240,000 | 9 | 26,667 |
| ធុងបាញ់ថ្នាំ ២០លីត្រ (ប្រើ៣ឆ្នាំ) | គ្រឿង | 1 | 120,000 | 120,000 | 9 | 13,333 |
| អាងស្តុកទឹក(ប្រើ១០ឆ្នាំ) | ឈុត | 1 | 2,000,000 | 2,000,000 | 30 | 66,667 |
| **៣-ចំណេញសរុប** | | | | | | 10,110,000 |
| ថ្លៃដើម/គ.ក | | | | | | 2,604 |
| ចំណេញ/គ.ក | | | | | | 4,396 |

**៥-លទ្ធភាពចំណេញផ្អែកលើនិន្នាការតម្លៃ** ÷ (លើផ្ទៃដីដាំដុះ១០ អា)

-តម្លៃទាបបំផុត ៦,០០០៛/គ.ក

-តម្លៃខ្ពស់បំផុត ៨,០០០៛/គ.ក

| ទិន្នផល គ.ក | តម្លៃ រៀល/គ.ក | ចំណូល រៀល | ចំណាយ រៀល | ចំណេញ-ខាត | |
|---|---|---|---|---|---|
| | | | | រៀល | % |
| 2,300 | 6,000 | 13,800,000 | 5,990,000 | 7,810,000 | 130.38% |
| 2,300 | 6,500 | 14,950,000 | 5,990,000 | 8,960,000 | 149.58% |
| 2,300 | 7,000 | 16,100,000 | 5,990,000 | 10,110,000 | 168.78% |
| 2,300 | 7,500 | 17,250,000 | 5,990,000 | 11,260,000 | 187.98% |
| 2,300 | 8,000 | 18,400,000 | 5,990,000 | 12,410,000 | 207.18% |

**៦-ខ្សែច្រវ៉ាក់តម្លៃ÷**

កសិករ÷ លក់៧,០០០៛/គ.ក - ថ្លៃដើម ២,៦០៤៛/គ.ក = ចំណេញ ៤,៣៩៦៛/គ.ក

ឈ្មួញកណ្តាល÷ បោះដុំ ១០,០០០៛/គ.ក(ថ្លៃដឹកជញ្ជូន ៥០០៛/គ.ក) ចំណេញ ២៥០០៛/គ.ក

អ្នកលក់រាយ÷ លក់១២,០០០៛/គ.ក(ជួលតូប និងខូចខាត៥០០៛/គ.ក) ចំណេញ ១៥០០៛/គ.ក

## ៧-ហានិភ័យ ÷

តាមរយៈនៃការចុះសិក្សាផ្ទាល់ពីកសិករដាំដុះម្ទេសហាវៃ នៅសង្កាត់រលាប ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ មានហានិភ័យមួយចំនួនអាចកើតឡើងជាយថាហេតុលើដំណើរការដាំដុះ ដូចជា÷

| ល.រ | ប្រភេទហានិភ័យ | ពិពណ៌នាហានិភ័យ | វិធានការ |
|---|---|---|---|
| | **ហានិភ័យផលិតកម្ម** | ទិន្នផលធ្លាក់ចុះ បណ្តាលមកពីកត្តា<br>- ជំងឺផ្សិត ណេម៉ាតូដ<br>- ផ្លែម្ទេសហាវៃ មិនសូវធំ | -គួរប្រើប្រាស់វិធានការការពារដំណាំ និងមានកាលវិភាគប្រើប្រាស់ថ្នាំត្រឹមត្រូវសម្រាប់សត្វល្អិត និងជំងឺ<br>-ប្រើប្រាស់ថ្នាំជីវសាស្ត្រ មុនពេលចាប់ផ្តើមដាំដុះ<br>-ជ្រើសរើសពូជធន់នឹងកត្តាចង្រៃ និងអាកាសធាតុ<br>-សិក្សាការជ្រើសរើសពូជផ្លែធំ អាកាសធាតុ ការកែប្រែគុណភាពដី និងការគ្រប់គ្រងជីសម្រាប់ដំណាំ |

## ៨-សេចក្តីសន្និដ្ឋាន

ដំណាំម្ទេសហាវៃ គឺជាដំណាំងាយស្រួលថែទាំ មានអាយុកាលខ្លី មិនសូវខ្វះទីផ្សារនោះទេ ព្រោះមានឈ្មួញមកទទួលទិញដល់ចម្ការ ដើម្បីលក់ចែកចាយទៅទីផ្សារក្នុងស្រុក និងនៅផ្សារទំនើបក្នុងទីក្រុងភ្នំពេញ និងតាមបណ្តាខេត្តនានា ដោយលក់ក្នុងតម្លៃបោះដុំ៦,០០០-៨,០០០៛/គ.ក ជាតម្លៃដែលកសិករមានលទ្ធភាពចំណេញ។

## ប្រភពនៃការសិក្សាស្រាវជ្រាវ ÷

-កសិករដាំដុះម្ទេសហាវៃ នៅសង្កាត់រលាប ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់

-ឯកសារបច្ចេកទេសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ